# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1536

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងវិទ្យាស្ថានអប់រំ ស្រាវជ្រាវសិល្បៈនិងវប្បធម៌

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/09/23 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 30/09/25 |

៣. ចំណាយគម្រោងសរុប $4,600,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

| | |
|---|---|
| RESPONSIBLE UNIT | Royal University of Fine Arts |
| អង្គភាពទទួលខុសត្រូវ | សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ |

៥. ស្ថានភាពគម្រោង គម្រោងកំពុងដំណើរការ

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

បញ្ចកោណទី១- ការអភិវឌ្ឍមូលធនមនុស្ស

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

- ចូលរួមពង្រឹងការបណ្តុះបណ្តាលលើកិច្ចការស្រាវជ្រាវ និងកសាងសមត្ថភាពជូនដល់សិល្បៈករ មន្រ្តីរាជការ សាស្រ្តាចារ្យ សិស្សហាត់ការជំនាញសិល្បៈនាដសាស្រ្ត និងតូរ្យតន្រ្តី។
- បង្កើតគោលនយោបាយអប់រំសិល្បៈ និងលើកកម្ពស់ការអប់រំសិល្បៈជាតិសម្រាប់កុមារ និងយុវជនដោយធ្វើពិពិធកម្មវិធីអប់រំ សិល្បៈ។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? គាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

វប្បធម៌ និងសិល្បៈ

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

រាជធានីភ្នំពេញ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

-បង្កើនបរិក្ខា និងធ្វើឱ្យដំណើរការនៃវិទ្យាស្ថានស្រាវជ្រាវសិល្បៈ (តន្ត្រី) មានភាពកាន់តែរស់រវើក។

-ពង្រឹងកម្រិតសមត្ថភាពសិល្បៈរបស់សិល្បៈករជំនាញ និងអ្នកពាក់ព័ន្ធក្នុងវិស័យអប់រំ ។

-ពង្រឹងសមត្ថភាពក្នុងការបង្កើតគោលនយោបាយទាក់ទងនឹងអប់រំសិល្បៈដល់មន្ត្រីរាជការ

-រៀបចំមូលដ្ឋានគ្រឹះក្នុងការផ្សព្វផ្សាយការអប់រំសិល្បៈ

-ផ្តល់ឱកាសក្នុងការចូលរួមសាកល្បងផ្ទាល់ក្នុងសកម្មភាពសិល្បៈ

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងវិទ្យាស្ថានអប់រំ ស្រាវជ្រាវសិល្បៈ និងវប្បធម៌គឺជាគម្រោងដែលផ្តោតលើការលើកកម្ពស់ការអប់រំសិល្បៈ និងជម្រុញឱ្យមានថ្នាក់អប់រំសិល្បៈនៅសាលារដ្ឋតាំងពីកម្រិតបឋមសិក្សារហូតដល់វិទ្យាល័យនាពេលអនាគត។ គម្រោងនេះនឹងបង្កើតឱ្យមានសាលសំដែង សាលតាំងពិព័ណ៌ និងជាមជ្ឈមណ្ឌលសម្រាប់ធ្វើការសិក្សាស្រាវជ្រាវផ្នែកសិល្បៈវប្បធម៌ជាពិសេសគឺសិល្បៈតូ្យតន្ត្រី។ គម្រោងនេះក៏ជាកន្លែងមួយដែលជួយបង្កើតឱ្យមានឧស្សាហកម្មវប្បធម៌ដោយធ្វើការបណ្តុះបណ្តាល ផ្លាស់ប្តូរបទពិសោធន៍ និងការបង្កើតថ្មីដែលជាផ្នែកមួយជម្រុញឱ្យមានចំណូលសេដ្ឋកិច្ចដល់អ្នកមានជំនាញវិជ្ជាជីវៈសិល្បៈ និងសង្គមទាំងមូល។ ខាងក្រោមបង្ហាញអំពីគោលដៅ លទ្ធផលរំពឹងទុក និងសមិទ្ធផលនៃគម្រោងក្នុងរយៈពេល ៣ឆ្នាំ។

1. គោលដៅ Objective

- ផ្តើមចេញពីការអប់រំតន្ត្រីទៅការលើកកម្ពស់ការយល់ដឹងអំពីការអប់រំសិល្បៈនិងជំរុញឱ្យការអប់រំថ្នាក់សិល្បៈ នៅសាលារដ្ឋមានភាពសកម្មនាពេលអនាគត

2. លទ្ធផល (Outcome)

- ផ្អែកលើលទ្ធផលនៃការដំណើរការវិទ្យាស្ថានស្រាវជ្រាវអប់រំសិល្បៈនឹងធ្វើឱ្យការអប់រំសិល្បៈមានភាពជាសាកល ភាវូបនីយកម្ម

- បង្កើតគ្រឹះសម្រាប់ឧស្សាហកម្មវប្បធម៌ដោយផ្តល់ការអប់រំសិល្បៈ និងឱកាសទទួលបានបទពិសោធន៍ផ្ទាល់

3. សមិទ្ធផល (Output)

- វិទ្យាស្ថានស្រាវជ្រាវអប់រំសិល្បៈត្រូវបានបង្កើត

- កម្មវិធីអប់រំសិល្បៈក្នុងប្រទេសកម្ពុជាត្រូវបានអភិវឌ្ឍន៍ថ្មី

- កម្មវិធីសិក្សា និងគោលនយោបាយនៃការអប់រំសិល្បៈក្នុងប្រទេសកម្ពុជាត្រូវបានអភិវឌ្ឍន៍ថ្មី

- កម្មវិធីទទួលបានបទពិសោធន៍ផ្ទាល់ពីសកម្មភាពសិល្បៈក្នុងប្រទេសកម្ពុជាត្រូវបានបង្កើតថ្មី

- មនុស្សត្រូវបានជ្រើសរើសមកធ្វើការដើម្បីដំណើរការគម្រោងក្នុងប្រទេសកម្ពុជា

- ដៃគូក្នុងស្រុកត្រូវបានជ្រើសរើសសម្រាប់បង្កើត និងដំណើរការគម្រោងប្រកបដោយជោគជ័យពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធ, សាស្ត្រាចារ្យ និងគ្រូបង្រៀន, សិល្បករជំនាញ (ក្រុម)

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

១) ប្រព័ន្ធអប់រំសិល្បៈថ្នាក់ជាតិ

ក) ប្រព័ន្ធអប់រំក្នុងប្រទេសកម្ពុជាត្រូវបានបែងចែកជាទូទៅមានថ្នាក់បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ និងមហាវិទ្យាល័យ

បឋមសិក្សាជាថ្នាក់ដែលប្រជាជនទូទៅមានកាតព្វកិច្ចចូលរៀន ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦, អនុវិទ្យាល័យ៣ឆ្នាំ (ថ្នាក់ទី៧ ដល់ថ្នាក់ទី៩), វិទ្យាល័យ ៣ឆ្នាំ (ពីថ្នាក់ទី១០ ដល់ទី១២) និងមហាវិទ្យាល័យមានរយៈពេល៤ឆ្នាំ។ ស្ថាប័នអប់រំជាតិ និងសាធារណៈទូទាំងប្រទេស មានចំនួន ៨,៨៩៩កន្លែង មានចំនួនគ្រូបង្រៀនសរុបប្រមាណ ៨៨,៤៨៤នាក់ ចំនួនសិស្សសរុប ប្រមាណ ២,៩៧១,៦៦៣ នាក់

ក្នុងនោះគ្រឹះស្ថានអប់រំរដ្ឋក្នុងទីក្រុងភ្នំពេញមានចំនួនសរុប២៣០កន្លែងដែលមានបឋមសិក្សា ចំនួន១៦១ សាលា, អនុវិទ្យាល័យ ៦៨សាលា, វិទ្យាល័យ ៤០សាលា និងមានចំនួនគ្រូប្រមាណ៥,០០០នាក់ ចំនួនសិស្សប្រមាណ ២២៥,៥៦៣នាក់ (ទិន្នន័យឆ្នាំ ២០១៩)

ការអប់រំក្នុងប្រទេសកម្ពុជាមានភាពខ្វះខាតនៅឡើយ ដោយជាមធ្យមគ្រូបឋមសិក្សាម្នាក់ត្រូវបង្រៀនសិស្ស ៤៤នាក់ វាជាចំនួនខ្ពស់បំផុតក្នុងចំណោមបណ្តាប្រទេសអាស៊ាន (ទិន្នន័យរបស់លេខាធិការដ្ឋានអាស៊ាន ឆ្នាំ២០១៧)

ខ) ដោយសារតែមិនមានមុខវិជ្ជាដែលទាក់ទងនឹងសិល្បៈដូចជាតន្ត្រី គំនូរ និងកីឡា ជាដើមក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ ដូច្នេះមិនត្រឹមតែ កុមារ យុវជន និងសិស្សានុសិស្សនោះទេ សូម្បីតែគ្រូបង្រៀនក៏សមត្ថភាពខាងផ្នែកនេះនៅមានកម្រិតនៅឡើយដែរ។

គ) ដើម្បីត្រៀមសម្រាប់ទស្សនវិស័យនៃកំណើនសេដ្ឋកិច្ចកម្រិតខ្ពស់របស់ប្រទេសកម្ពុជានាពេលអនាគត តម្រូវការការអប់រំសិល្បៈសម្រាប់ជាមូលដ្ឋានគ្រឹះនៃឧស្សាហកម្មវប្បធម៌ដែលមានតម្លៃបន្ថែមសេដ្ឋកិច្ចខ្ពស់ គឺចាំបាច់មិនអាចខ្វះបានទេ។ ដោយសារមិនមានស្ថាប័នស្រាវជ្រាវនិងអប់រំសម្រាប់ការបង្កើតប្រព័ន្ធអប់រំសិល្បៈ ដូច្នេះតម្រូវឱ្យបង្កើតស្ថាប័នជំនាញដើម្បីអភិវឌ្ឍន៍ និងដំណើរការគោលនយោបាយ កម្មវិធីសិក្សា និងកម្មវិធីផ្សេងទៀត។

២) ស្ថានភាពស្ថាប័នជំនាញអប់រំសិល្បៈ

ក) សាលាមធ្យមវិចិត្រសិល្បៈ (The Secondary School of Fine Arts) គឺជាសាលាពិសេសមួយដែលសិស្សអាចរៀនមុខវិជ្ជាទូទៅ និងជ្រើសរើសមុខវិជ្ជាជំនាញសម្រាប់រៀនក្នុងពេលទន្ទឹមគ្នា។

ខ) សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (The Royal University of Fine Arts) គឺជាស្ថាប័នជាតិតែមួយគត់ក្នុងប្រទេសកម្ពុជា ដែលបង្រៀនថ្នាក់សិល្បៈកម្រិតខ្ពស់ ដែលមានមហាវិទ្យាល័យចំនួន ៥ គឺមហាវិទ្យាល័យតូរ្យតន្ត្រី មហាវិទ្យាល័យសិល្បៈនាដសាស្ត្រ មហាវិទ្យាល័យសិល្បៈសូនរូប មហាវិទ្យាល័យបុរាណវិទ្យា និងមហាវិទ្យាល័យស្ថាបត្យកម្ម និងនគរូបនីយវិទ្យា។

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

អ្នកទទួលផលដោយផ្ទាល់៖

- អ្នកប្រើប្រាស់បរិក្ខាក្នុងវិទ្យាស្ថានស្រាវជ្រាវអប់រំសិល្បៈ (តន្ត្រី), អ្នកចូលរួមកម្មវិធីកសាងសមត្ថភាព (មន្ត្រីរាជការ សាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, គ្រូបន្ទុក, សិស្សដែលបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ សិស្សានុសិស្ស, គ្រូហាត់ការ, និងសិល្បករជំនាញ ជាដើម។
- អ្នកចូលរួមកម្មវិធីសិក្សាថ្នាក់ក្រៅម៉ោង (កុមារ យុវជន ជាដើម)

អ្នកទទួលផលដោយប្រយោល៖

- ប្រជាជនកម្ពុជា, អ្នកទេសចរ

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | ត្រូវបានរៀបចំ |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

១.បង្កើតការងារក្នុងវិស័យសិល្បៈតាមរយៈការបណ្តុះបណ្តាលគ្រូកម្មសិក្សានិងគ្រូសិល្បៈ សាស្ត្រាចារ្យ និងនិស្សិតដែលបញ្ចប់ការសិក្សានិងសិស្សដែលកំពុងសិក្សានៅសាកលវិទ្យាល័យវិចិត្រសិល្បៈក្នុងគោលបំណងកសាងធនធានមនុស្ស និងមូលធនមនុស្សក្នុងវិស័យវប្បធម៌ និងសិល្បៈ
២.បង្កើតម្លៃសេដ្ឋកិច្ច និងបង្កើតមូលដ្ឋានគ្រឹះនៃឧស្សាហកម្មវប្បធម៌ និងបង្កើនការយល់ដឹងអំពីសិល្បៈវប្បធម៌របស់ខ្លួនតាមរយៈការសម្តែងជូនភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិនៅទីក្រុងភ្នំពេញ។

## ១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|
| | | |

## ២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

គម្រោងនេះបានបែងចែកការគ្រប់គ្រងគម្រោងជាពីរផ្នែកគឺផ្នែកសាងសង់ និងផ្នែកបណ្តុះបណ្តាល។ ក្នុងផ្នែកសាងសង់មានសមាសភាពចំនួន ៦ រូប ហើយមានស្ត្រីមួយរូប ស្មើនឹង ១៦% ស្ថិតក្នុងតំណែងស្ថាបត្យករក្នុងការត្រួតពិនិត្យ និងវាយតម្លៃគុណភាពសំណង់
ចំពោះផ្នែកបណ្តុះបណ្តាលមានសមាសភាពចំនួន ៦រូប ហើយមានស្ត្រីចំនួន ២រូប ស្មើ ៣២% ស្ថិតក្នុងតំណែងគ្រប់គ្រងនឹងដឹកនាំការសម្តែង

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

១. ការងារសាងសង់៖ សមាសភាពអ្នកអនុវត្តគម្រោងមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការសហការសាងសង់ជាមួយដៃគូកូរ៉េ (មានស្ថាបត្យករក្នុងការគ្រប់គ្រង និងវាយតម្លៃគម្រោងសាងសង់តាមបទដ្ឋានបច្ចេកទេសសំណង់) និង
២. ការងារបណ្តុះបណ្តាល៖

២៣. [illegible]
ឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

១. ការងារសាងសង់៖ នៅក្នុងខែ កញ្ញា ឆ្នាំ ២០២៣ គម្រោងបានជ្រើសរើសក្រុមហ៊ុនសិក្សាប្លង់រួចរាល់ ហើយបច្ចុប្បន្ននេះក្រុមហ៊ុនកំពុងសិក្សាប្លង់បច្ចេកទេសស្ថាបត្យកម្ម
២. ការងារបណ្តុះបណ្តាល៖ បានបណ្តុះបណ្តាលវគ្គកម្រិតមូលដ្ឋានដល់សិក្ខាកាមចំនួន ៣០០ នាក់ នៅខែ កញ្ញា ឆ្នាំ ២០២៣ និងវគ្គបណ្តុះបណ្តាលជាន់ខ្ពស់ចំនួន ២០ នាក់ នៅខែ វិច្ឆិកា ឆ្នាំ ២០២៣។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

2

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**ក្រសួងអប់រំ កីឡា និងទេសចរណ៍ សាធារណៈកូរ៉េ តាមរយៈអង្គការ** (KOFICE)

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 650.0 | 350.0 | 4,250.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 450.0 | 150.0 | 3,450.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 200.0 | 200.0 | 800.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 650.0 | 350.0 | 4,250.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ថ៉ាន់ស្មាន | ថ៉ាន់ស្មាន | ថ៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 650.0 | 350.0 | 4,250.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| Republic of Korea | 650.0 | 350.0 | 4,250.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 650.0 | 350.0 | 4,250.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: